អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងជិតចិត្តរបស់ ខៀវ សំផន ចំពោះចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលចំនួន ០៦ រូប ដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១។

នៅថ្ងៃទី៣១ ខែតុលាឆ្នាំ ២០១៩ សហមេធាវីការពារក្តី ខៀវ សំផន បានដាក់បណ្តឹងជិតចិត្ត និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ដកចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលទាំង ០៦ រូបដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាព្រមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបរៀងៗខ្លួនទៅនឹងបណ្តឹងជិតចិត្តនេះ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ គណៈកម្មាធិការរដ្ឋបាលតុលាការបានសម្រេចជាឯកច្ឆន្ទលើសមាសភាព នៃក្រុមប្រឹក្សាជំនុំជម្រះពិសេស ដើម្បីសម្រេចសេចក្តីលើបណ្តឹងជិតចិត្តរបស់ ខៀវ សំផន។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបង្ហាញមូលដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននូវបណ្តឹងជិតចិត្តចៅក្រម ហើយបានសម្រេចជាឯកច្ឆ័ន្ទថា បណ្តឹងជិតចិត្តរបស់ ខៀវ សំផន អាចទទួលយកបាន (កថាខណ្ឌ ២២-៤៣)។

ចំពោះអង្គសេចក្តីនៃបណ្តឹងជិតចិត្ត ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបង្ហាញបទដ្ឋានគតិយុត្តិជាធរមានសម្រាប់ប្តឹងជិតចិត្តចៅក្រម និងបានសម្រេចថា ការចោទប្រកាន់អំពីបុរេវិនិច្ឆ័យលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ (កថាខណ្ឌ ៦២-៨៧) និងការសន្និដ្ឋានមិនត្រឹមត្រូវនៅក្នុងសាលដីកាសំណុំរឿង ០០២/០១ (កថាខណ្ឌ ១០០-១១២) ព្រមទាំងភាពមិនប្រាកដប្រជានៃនីតិវិធី ក្រោយការប្រកាសសាលក្រមសំណុំរឿង ០០២/០២ (កថាខណ្ឌ ១១៩-១២៤) មិនគ្រប់គ្រាន់អាចបដិសេធសច្ចធារណ៍ដ៏រឹងមាំនៃភាពមិនលំអៀងរបស់ចៅក្រមដែលរងបណ្តឹងជិតចិត្តនោះឡើយ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានច្រានចោលបណ្តឹងជិតចិត្តលើអង្គសេចក្តីទាំងស្រុង។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស អាចរកមើលបាននៅលើគេហទំព័រ៖

https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/11_KH.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក នេត្រ ភក្ត្រា

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ

ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.phektra@eccc.gov.kh